ចក្ខុវិស័យសម្រាប់

# អនាគតនៃការដឹកជញ្ជូននៅទីក្រុង Seattle

Seattle Department of Transportation

## ផែនការដឹកជញ្ជូនរបស់ទីក្រុង SEATTLE

### សេចក្តីសង្ខេប | ខែ សីហា ២០២៣

ផែនការដឹកជញ្ជូននៃទីក្រុង **Seattle (STP)** គឺជាគម្រោង ២០ ឆ្នាំទៅអនាគតនៃការដឹកជញ្ជូននៅក្នុងទីក្រុង Seattle ។ វានឹងជួយណែនាំពីរបៀបដែលយើងធ្វើទំនើបកម្ម និងថែរក្សាប្រព័ន្ធដឹកជញ្ជូនរបស់យើង ដើម្បីភ្ជាប់មនុស្សទៅនឹងឱកាស ធម្មជាតិប្រកបដោយនិរន្តរភាពហើយនិងទៅវិញទៅមកនិងគ្នា។ វាគឺជាផែនការដើម្បីផ្តល់នូវជម្រើសនៃការធ្វើដំណើរដែលអាចទុកចិត្តបានសម្រាប់មនុស្សនិងទំនិញ ហើយនិងដើម្បីស្រមៃមើលទៅលើផ្លូវឡើងវិញថា វាជាកន្លែងសម្រាប់ស្វាគមន៍មនុស្ស វប្បធម៌ អាជីវកម្ម ការកម្សាន្ត និងការជួបជុំគ្នា។ វាគឺជាឱកាសមួយដើម្បីមកជួបជុំគ្នា — ជាទីក្រុង Seattle តែមួយ (One Seattle)។

សេចក្តីសង្ខេបរបស់ **STP** គូសបញ្ជាក់ផ្នែកសំខាន់ៗនៃផែនការ។ ព័ត៌មានបន្ថែមអាចរកបាននៅក្នុងឯកសារ STP ទាំងមូល (សូមមើលលេខកូដដែលអាចស្កេនបាននៅខាងខ្នងខិត្តប័ណ្ណនេះ)។

## ចក្ខុវិស័យ

លទ្ធផលនៃការសន្ទនារយៈពេលមួយឆ្នាំជាមួយមនុស្សទូទាំងទីក្រុង Seattle ។

ទីក្រុង **Seattle** គឺជាទីក្រុងប្រកបដោយសមធម៌ ភាពរស់រវើក និងចម្រុះជាតិសាសន៍ ដែលជាកន្លែងមានសុវត្ថភាព មានយុត្តិធម៌និងនិរន្តរភាពសម្រាប់ធ្វើដំណើរជុំវិញទីក្រុង។ មនុស្សនិងអាជីវកម្មទាំងអស់អាចទទួលបានតម្រូវការប្រចាំថ្ងៃរបស់ពួកគេ ហើយមានអារម្មណ៍ថាមានទំនាក់ទំនងជាមួយសហគមន៍របស់ពួកគេ។

## គោលដៅ

ដោយបានបង្កើតឡើងដោយប្រជាជននៃទីក្រុង Seattle គោលដៅទាំងនេះជួយយើងធ្វើការសម្រេចចិត្តអំពីអនាគតនៃការដឹកជញ្ជូនរបស់យើង។

### សុវត្ថិភាព

សុវត្ថិភាពគឺជាអាទិភាពសម្រាប់អ្នកធ្វើដំណើរក្នុងទីក្រុង Seattle ដែលប្រកបដោយគ្មានការរបួសធ្ងន់ធ្ងរ ឬគ្រោះថ្នាក់ដល់ជីវិត

### សមធម៌

សហការគ្នាជាមួយសហគមន៍ដើម្បីបង្កើតនិងចាប់ផ្តើមស្តារការអនុវត្តឡើងវិញ ដើម្បីដោះស្រាយវិសមភាពទាក់ទងនឹងការដឹកជញ្ជូន

### ស្ថេរភាព

ឆ្លើយតបទៅនឹងការប្រែប្រួលនៃអាកាសធាតុ តាមរយៈការប្រឌិតថ្មីៗ និងតាមរយៈកញ្ចក់ឆ្លុះបញ្ចាំងយុត្តិធម៌អាកាសធាតុ

### ការធ្វើដំណើរ

ផ្តល់ជម្រើសធ្វើដំណើរដែលអាចទុកចិត្តបាន និងតម្លៃសមរម្យដែលអាចឱ្យប្រជាជនធ្វើដំណើរនិងការដឹកទំនិញទៅដល់កន្លែងដែលត្រូវទៅដល់

### ជីវភាព

ស្រមៃមើលផ្លូវក្នុងទីក្រុងឡើងវិញថា ជាកន្លែងសម្រាប់អញ្ជើញឱ្យដើរលេងនិងលេងកំសាន្ត

### ការថែទាំ និងទំនើបកម្ម

កែលម្អហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនក្នុងទីក្រុង និងត្រៀមជាស្រេចសម្រាប់អនាគតកាល

# សកម្មភាពសំខាន់ៗ

សកម្មភាពសំខាន់ៗជួយយើងឱ្យសម្រេចបាននូវចក្ខុវិស័យ និងគោលដៅរបស់ STP ។ ដើម្បីអោយទីក្រុង Seattle ធ្វើការផ្លាស់ប្តូរបានល្អៗលឿនជាងមុន យើងត្រូវប្រើវិធីសាស្រ្តដែលគេស្គាល់ថា មានប្រសិទ្ធភាព និងសាកល្បងវិធីថ្មីៗដែលត្រូវនឹងអ្វីដែលសហគមន៍របស់យើងចង់បាន។

## សុវត្ថិភាព

- កាត់បន្ថយល្បឿនរថយន្ត ដើម្បីបង្កើនសុវត្ថិភាព
- ផ្តោតការវិនិយោគទៅលើសុវត្ថិភាពនៅតាមទីតាំងដែលងាយមានគ្រោះថ្នាក់ខ្លាំងបំផុត
- ធ្វើឱ្យការធ្វើដំណើរទាំងអស់មានសុវត្ថិភាពជាងមុន ចាប់ពីកន្លែងចេញដំណើរទៅដល់ទិសដៅ
- ផ្តល់ផ្លូវដែលមានសុវត្ថិភាពជាងមុនទៅកាន់សាលារៀន សួនឧទ្យាន យានយន្តធ្វើដំណើរ កន្លែងប្រមូលផ្តុំសហគមន៍ និងគោលដៅទូទៅផ្សេងៗទៀត

## ស្ថេរភាព

- កែលម្អគុណភាពខ្យល់ក្នុងតំបន់ និងលទ្ធផលសុខភាពដោយលើកកម្ពស់ជម្រើសនៃការធ្វើដំណើរប្រកបដោយនិរន្តរភាពនិងស្អាតស្អំ
- ធ្វើអោយផ្លូវក្នុងទីក្រុងខៀវស្រងាត់ តាមរយៈការដាំរុក្ខជាតិ និងដើមឈើតាមដងផ្លូវ ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុអោយបានប្រសើរជាងមុន
- លើកកម្ពស់ភាពរស់រវើកក្នុងតំបន់រស់នៅ និងលើកកម្ពស់សុខភាពក្នុងសហគមន៍
- គាំទ្រការផ្លាស់ប្តូរពីប្រេងឥន្ធនៈហ្វូស៊ីលទៅជារថយន្តអគ្គិសនីសម្រាប់ការធ្វើដំណើរផ្ទាល់ខ្លួន ពាណិជ្ជកម្ម និងការដឹកជញ្ជូន
- យុទ្ធសាស្រ្តគ្រប់គ្រងការធ្វើដំណើរបែបទំនើប ដើម្បីលើកទឹកចិត្តឱ្យដើរ ជិះកង់ និងការធ្វើដំណើរតាមយានជំនិះក្រុង

## ជីវភាព

- រៀបចំទីតាំងឡើងវិញយ៉ាងយកចិត្តទុកដាក់ ដោយទុកផ្លូវសម្រាប់ឱ្យមនុស្សអាចចេញចូលបាន អំឡុងពេលពួកគេត្រូវដឹកជញ្ជូនទំនិញនិងនាពេលមានអាសន្ន
- ផ្លាស់ប្តូរមជ្ឈមណ្ឌលរបស់សហគមន៍ និងការធ្វើដំណើរអោយក្លាយទៅជាកន្លែងជាទីស្វាគមន៍
- សហការបង្កើត និងលើកកំពស់ទីធ្លាសាធារណៈសម្រាប់ការលេងកំសាន្ត និងការជួបជុំ ដើម្បីលើកកម្ពស់សុខភាពសហគមន៍
- ធ្វើឱ្យសកម្ម និងរក្សាកន្លែងសាធារណៈ ដើម្បីបង្កើតទីតាំងសាធារណៈដែលជាទីស្វាគមន៍ និងសមស្របតាមអាយុ

## សមធម៌

- ផ្តោតលើសម្លេងរបស់សហគមន៍ដែលមិនមែនជាជនជាតិស្បែកសនិងក្រុមដែលមានតំណាងតិចតួចនៅក្នុងដំណើរការរៀបចំផែនការ
- ដោះស្រាយវិសមភាពក្នុងប្រព័ន្ធដឹកជញ្ជូនដោយផ្តល់អាទិភាពដល់ការវិនិយោគសម្រាប់សហគមន៍ដែលរងផលប៉ះពាល់
- លុបបំបាត់ការចំណាយដែលជាឧបសគ្គ ដូច្នោះមនុស្សគ្រប់គ្នាអាចធ្វើដំណើរដែលពួកគេត្រូវការ

## ការធ្វើដំណើរ

- បង្កើតការតភ្ជាប់ការធ្វើដំណើរដោយរលូន
- ធ្វើឱ្យជម្រើសនៃការដើរ ជិះកង់ និងងាយស្រួលក្នុងការជិះកង់រមៀល និងធ្វើដំណើរដោយរីករាយ
- បង្កើតការប្រើប្រាស់ក្នុងការធ្វើដំណើរលំដាប់ពិភពលោក និងធ្វើឱ្យមានសេវាកម្មកាន់តែច្រើនញឹកញាប់និងគួរឱ្យទុកចិត្ត
- បង្កើនភាពរឹងមាំខាងសេដ្ឋកិច្ចដោយគាំទ្រចលនាដឹកជញ្ជូន និងកំណើននៃការចែកចាយ
- គ្រប់គ្រងទីធ្លាតាមចិញ្ចើមថ្នល់ដើម្បីឆ្លុះបញ្ចាំងពីគោលដៅ និងអាទិភាពរបស់ទីក្រុង

## ការថែទាំ និងទំនើបកម្ម

- ផ្លាស់ប្តូរផ្លូវក្នុងទីក្រុង ដើម្បីឱ្យមានសុវត្ថិភាព និងជម្រើសនៃការធ្វើដំណើរប្រកបដោយនិរន្តរភាព តាមរយៈពេលការជួសជុលនិងកែលម្អដ៏ល្អប្រសើរឡើងវិញ
- កាត់បន្ថយភាពមិនស្មើគ្នានៅក្នុងតំបន់រស់នៅតាមរយៈគុណភាពផ្លូវ ចិញ្ចើមផ្លូវ ទីសាធារណៈ និងស្ពាន
- ត្រៀមផ្លូវទីក្រុងអោយរួចរាល់សម្រាប់ជម្រើសធ្វើដំណើរថ្មី និងនិន្នាការ និងបច្ចេកវិទ្យាដែលកំពុងរីកចម្រើន

## ការចូលរួម សង្ខេប

តាមរយៈការចូលរួមរបស់ STP យើងបានទាក់ទងមនុស្សរាប់ពាន់នាក់—ដើម្បីបង្កើតការយល់ដឹង ស្តាប់មតិកែលម្អ និងសហការបង្កើតចក្ខុវិស័យនាពេលអនាគតនៃការដឹកជញ្ជូននៅទីក្រុង Seattle។

**ជាង 76,000**
ចំណុចនៃទិន្នន័យនីមួយៗដែលប្រមូលបានតាមរយៈការចូលរួមរបស់ STP

**ជាង 7,000**
មនុស្សដែលបានចូលរួមនៅក្នុងព្រឹត្តិការណ៍ផ្សព្វផ្សាយរបស់ STP



# យើងបានស្នើសុំឱ្យអ្នកបង្កើត STP ជាមួយយើង-ហើយនេះគឺជាអ្វីដែលយើងបានឮ។

"ពេលវេលាសម្រាប់អនុវត្តហួសពេលយូរមកហើយ" ។

"ការដឹកជញ្ជូន គួរតែមានតម្លៃសមរម្យសម្រាប់មនុស្សគ្រប់រូប ដោយថាមនុស្សគ្រប់រូបគួរអាចប្រើមធ្យោបាយធ្វើដំណើរ ដើរ ឬជិះកង់ក្នុងតម្លៃថោក»។

"ធ្វើឲ្យបណ្តាញដឹកជញ្ជូនសាធារណៈរបស់យើងកាន់តែប្រសើរឡើង ហើយសំខាន់ជាងនេះទៅទៀត ផ្តល់អាទិភាពដល់អ្នកដែលមិនបើកបរនូវ ទីធ្លាផ្លូវធ្វើដំណើររបស់យើង។ បង្កើតផ្លូវជិះកង់ និងផ្លូវធ្វើដំណើរឱ្យមានកាន់តែច្រើននៅលើច្រករបៀងសំខាន់ៗរបស់យើង ដោយដកចេញនូវផ្លូវធ្វើដំណើរទូទៅ និងចំណតចតឡាននៅតាមដងផ្លូវនៅពេលណាដែលចាំបាច់ត្រូវធ្វើ។ វាត្រូវតែមានសុវត្ថិភាព និងងាយស្រួលក្នុងការប្រើប្រាស់សេវាកម្មទាំងនេះ"

"យកចិត្តទុកដាក់ចំពោះប្រជាជនភាគច្រើនដែលចង់បានមធ្យោបាយដែលមានសុវត្ថិភាព សមភាព និងការធន់នឹងអាកាសធាតុបន្ថែមទៀតជាងកាលពីមុនដើម្បីធ្វើដំណើរទៅមកជុំវិញទីក្រុង Seattle "។

"ការសម្រួលចរាចរណ៍ដឹកទំនិញ និងពាណិជ្ជកម្ម ជាពិសេសភាគខាងជើងនៃផ្លូវកប៉ាល់ធ្វើដំណើរ។ ដោយមានច្រកផ្លូវរបៀងសម្រាប់ចរាចរណ៍ឆ្លាស់គ្នាឱ្យបានគ្រប់គ្រាន់ក្នុងករណីមានអាសន្ន ពោលគឺការរញ្ជួយផែនដី និង/ឬរលកយក្សស៊ូណាមិ»។

"ការជួសជុលគឺមិនមែនជាទដ្ឋភាពល្អទេ ប៉ុន្តែវាការងារមួយដ៏សំខាន់ដើម្បីធ្វើឱ្យទីក្រុងរបស់យើងដំណើរការបានប្រក្រតី"

"ចំនួនប្រជាជន ភាពចម្រុះជាតិសាសន៍ និងជីវភាពក្នុងសហគមន៍ផ្តល់នូវសមធម៌ដោយស្វ័យប្រវត្ត។ មានលំនៅដ្ឋាន ការងារ កន្លែងកំសាន្ត និងឱកាសប្រកបអាជីវកម្មកាន់តែច្រើនសម្រាប់ពួកយើងទាំងអស់គ្នា!"

"យើងត្រូវការការដឹកជញ្ជូនលឿន មានសុវត្ថិភាព និងតម្លៃសមរម្យ ដែលមិនតម្រូវឱ្យដើរលើសពីពីរបីប្លុកទៅកាន់មជ្ឈមណ្ឌល"។

"នៅពេលដែលមានការធ្វើផែនការនិងការចូលរួមបានល្អ គួរតែមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។"

"សមធម៌គួរតែស្ថិតនៅជាគោលនៃរាល់គំនិតផ្តួចផ្តើម។ ការកែលម្អជម្រើសនៃការដឹកជញ្ជូន/សុវត្ថិភាពនៅក្នុងតំបន់រស់នៅដែលមានការដឹកជញ្ជូនគ្រប់គ្រាន់/សុវត្ថិភាព... គួរតែកើតឡើងបន្ទាប់ពីការកែលម្អតំបន់ដែលមិនត្រូវបានអើពើពីមុនមក។"

## នេះជារបៀបដែលយើងបានយកមតិកែលម្អរបស់អ្នកមកប្រើ។

**ព័ត៌មានអំពីរបៀបដែលយើងនឹងធ្វើការផ្សព្វផ្សាយនាពេលអនាគត**
ការចូលរួម

**ទិសដៅគោលនយោបាយដែលឆ្លុះបញ្ចាំងពីតម្លៃទីក្រុង**
គោលនយោបាយ

**ណែនាំអំពីកន្លែង និងអ្វីដែលយើងវិនិយោគដំបូង**
ការផ្តល់អាទិភាព

**ផែនទីដែលបង្ហាញយើងពីកន្លែងដែលត្រូវកែលម្អ**
បណ្តាញវិនិយោគ

**យុទ្ធសាស្រ្តសម្រាប់របៀបដែលយើងចំណាយទៅលើ និងការអនុវត្តផែនការ**
ការអនុវត្តយុទ្ធសាស្រ្ត

**គម្រោង និងកម្មវិធីដើម្បីកែលម្អប្រព័ន្ធដឹកជញ្ជូន**
តម្រូវការរបស់កម្មវិធី និងគម្រោង

**គោលដៅដែលតាមដានវឌ្ឍនភាព**
វិធានការអនុវត្ត

# សមាសភាគរបស់ STP

នៅក្នុងផ្នែកទី 1 នៃ STP យើងនិយាយអំពីរបៀបដែលផ្នែកផ្សេងៗនៃប្រព័ន្ធដឹកជញ្ជូនដែលធ្វើការជាមួយគ្នាដើម្បីសម្រេចបាននូវគោលដៅរបស់យើង។ ផ្នែកទី II មានជំពូកពិសេសសម្រាប់វិធីជាក់លាក់ដើម្បីធ្វើដំណើរទៅមក និងវិធីសំខាន់ៗដែលយើងប្រើប្រាស់ផ្លូវរបស់យើង។ សមាសភាគទាំងនេះបង្ហាញពីផែនការដ៏ធំរបស់យើងដើម្បីគាំទ្រដល់គោលដៅសំខាន់ៗ និងការផ្លាស់ប្តូរគន្លឹះនៃផែនការ។ សមាសភាគមួយចំនួនក៏មានផែនទីដែលបង្ហាញពីកន្លែងដែលយើងនឹងផ្តោតទៅលើមុនគេ។

STP រួមមានប្រាំបីសមាសភាគ៖

- អ្នកថ្មើរជើង
- កង់និងការធ្វើដំណើរតាមប្រព័ន្ធដែលប្រើចរន្តភ្លើង e-Mobility
- ការធ្វើដំណើរ
- ការដឹកទំនិញនិងការដឹកជញ្ជូនតាមទីក្រុង
- ផ្លូវសម្រាប់មនុស្សដើរនិងទីកន្លែងសាធារណៈ
- ការគ្រប់គ្រងចិញ្ចើមផ្លូវ
- ការធ្វើដំណើរបែបថ្មី ហើយនិងកំពុងអភិវឌ្ឍ
- យានយន្ត

# ការអនុវត្តផែនការ

ប្រជាជននៅទីក្រុង Seattle បានប្រាប់យើងថា ពួកគេចង់បានការផ្លាស់ប្តូរដ៏ធំ និងឆាប់រហ័សចំពោះរបៀបដែលពួកគេធ្វើដំណើរជុំវិញទីក្រុង។ យើងចង់បានគំនិតរបស់អ្នកអំពីរបៀបដែលផែនការពង្រាងនេះឆ្លើយតបនឹងចក្ខុវិស័យ STP របៀបដែលយើងនឹងសម្រេចចិត្តថា ត្រូវធ្វើអ្វីមុនគេ និងរបៀបដែលយើងនឹងស្វែងរកថវិកា។ ដោយវិធីនេះ យើងអាចផ្តល់ឱ្យអ្នកនូវការផ្លាស់ប្តូរដែលអ្នកចង់បាន។

## មូលហេតុដែលយើងត្រូវការផែនការនេះ

នៅពេលយើងលើកយកបញ្ហាសំខាន់ៗនៅថ្ងៃនេះ យើងក៏ត្រូវគិតអំពីរបៀបដែលប្រព័ន្ធដឹកជញ្ជូនរបស់យើងនឹងផ្លាស់ប្តូរតាមពេលវេលា ដើម្បីបំពេញតម្រូវការនាពេលអនាគតរបស់យើង។

យើងត្រូវការផែនការដើម្បីជួយយើងធ្វើការសម្រេចចិត្តដ៏ឆ្លាតវៃ និងវិនិយោគក្នុងដំណោះស្រាយដែលត្រូវនឹងលិទ្ធ និងគោលដៅរបស់ទីក្រុងរបស់យើងសម្រាប់ពេលអនាគត។

## ផែនការនេះជំរុញលទ្ធផលទាំង ៧ នេះ៖

- ការពារដល់មនុស្ស
- វិនិយោគលើសមធម៌
- បង្កើនការដឹកជញ្ជូនបៃតង
- តភ្ជាប់ការងារ និងលំនៅដ្ឋាន
- ពង្រីកការចូលប្រើដែលមានតម្លៃសមរម្យ
- ឆ្លុះបញ្ចាំងពីអាទិភាពនៃសហគមន៍
- វិវឌ្ឍ និងច្នៃប្រឌិតជាមួយនិន្នាការដែលកំពុងរីកចម្រើន



## សូមអរគុណចំពោះការចូលរួមក្នុងការបង្កើតផែនការដឹកជញ្ជូននៃទីក្រុង Seattle! យើងទន្ទឹងរង់ចាំបន្តធ្វើការជាមួយអ្នក និងអ្នកជិតខាងរបស់អ្នក ដើម្បីបង្កើតប្រព័ន្ធដឹកជញ្ជូនដែលបំពេញតាមតម្រូវការរួមគ្នារបស់យើង។

តើអ្នកត្រូវការពត៌មាន មានសំណួរ កង្វល់ ឬមានមតិយោបល់អ្វីបន្ថែមឬទេ?

សូមផ្ញើអ៊ីមែលមកយើង៖ **STP@Seattle.gov**

ទូរស័ព្ទទៅខ្សែសារជាសំឡេងរបស់យើង៖ **206-257-2114**

ចូលទៅកាន់មជ្ឈមណ្ឌលទំនាក់ទំនង STP៖ **ប្រើលេខកូដដែលអាចស្កេនបាន។**